**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ធនាគារជាតិ នៃ កម្ពុជា**

លេខ..........០២៣៥/១៧ ធ.ក.ជ..........

រាជធានីភ្នំពេញ ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០១៧

# សេចក្តីជូនដំណឹង
## ស្តីពី យុទ្ធនាការស្រលាញ់ប្រាក់រៀល

ធនាគារជាតិនៃកម្ពុជាមានសេចក្តីសោមនស្សរីករាយ សូមជម្រាបជូនសាធារណជនឱ្យបានជ្រាបថា ដើម្បីរួមចំណែកអបអរសាទរថ្ងៃចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំរកា នព្វស័ក ព.ស. ២៥៦១ ធនាគារជាតិនៃកម្ពុជានឹងរៀបចំយុទ្ធនាការស្រលាញ់ប្រាក់រៀលចាប់ពីថ្ងៃទី១០ ដល់ថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៧។

យុទ្ធនាការនេះ នឹងផ្តល់ឱកាសជូនសាធារណជនដែលមានបំណងប្តូរក្រដាសប្រាក់រៀលចាស់ ទក់ ឬរហែក ជាមួយនឹងក្រដាសប្រាក់ថ្មីពីធនាគារជាតិនៃកម្ពុជា។ ការប្តូរក្រដាសប្រាក់នេះ នឹងប្រព្រឹត្តទៅនៅគ្រប់សាខាធនាគារជាតិនៃកម្ពុជារាជធានី-ខេត្ត (លើកលែងស្នាក់ការកណ្តាល)។

ក្នុងឱកាសនៃពិធីចូលឆ្នាំថ្មីនេះ ធនាគារជាតិនៃកម្ពុជា សូមជូនពរ សម្តេច ឯកឧត្តម លោកជំទាវ អ្នកឧកញ៉ា លោក លោកស្រីទាំងអស់ សូមជួបប្រទះតែពុទ្ធពរទាំងបួនប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**អគ្គទេសាភិបាល**

Thays

**ជា_យ៉ាវ**

**ទំនាក់ទំនង៖**
ទូរស័ព្ទ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល៖ nbccommunication@nbc.org.kh